ប្រការ ៣ ៖ ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

ប្រការ ៤ ៖ គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ។

ប្រការ ៥ ៖ គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៦ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ២០ សសរ.

## ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាព នៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ ៖ បង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាពនៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង ដែលមានសមាសភាព ដូចតទៅ ៖

១- លោកជំទាវ លី វួចឡេង រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ប្រធាន

២- ឯកឧត្តមឧត្តមសេនីយ៍ត្រី សៅ សុខា មេបញ្ជាការរងនៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៣- ឯកឧត្តម ម៉ុល លីម អគ្គាធិការរងក្រសួងមហាផ្ទៃ សមាជិក

៤- លោក យ៉ា សុខហាក់ ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៥- តំណាងអាជ្ញាធរខេត្តព្រៃវែង សមាជិក

៦- តំណាងអាជ្ញាធរស្រុកពាមជ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- ចុះស្រាវជ្រាវ និងលើកវិធានការដោះស្រាយឲ្យមានប្រសិទ្ធភាព នូវរាល់បាតុភាពដែលកើតមានឡើងនៅភូមិខ្សាច់ ឃុំកោះសំពៅ ស្រុកពាមជ ខេត្តព្រៃវែង ។
- ធ្វើរបាយការណ៍អំពីវិធានការដោះស្រាយ និងលទ្ធផលនៃការងារខាងលើ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះ មានប្រសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សំរាប់សំរួលការងារ ។

**ប្រការ ៤:** បទបញ្ញត្តិទាំងឡាយណាផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងលោកជំទាវ ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★